JESUS
316

# តើព្រះយេស៊ូវជានរណា?

**តើព្រះយេស៊ូវជានរណា?** ព្រះគម្ពីរផ្ដល់ឱ្យយើងនូវចម្លើយពិតតែមួយគត់ចំពោះសំណួរនោះ។ លោកសាវកប៉ុលបានសរសេរថា *«គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណ* [ខ្យល់ដង្ហើម] *បណ្ដាលឲ្យតែងទេ...»* ២ ធីម៉ូថេ ៣:១៦។ ព្រះគម្ពីរគឺជាព្រះវិញ្ញាណនៃព្រះ នៅក្នុងលោកុប្បត្តិដល់វិវរណៈ បង្រៀនថា ព្រះយេស៊ូវជាព្រះអស់កល្បពីអតីតកាល ដល់អនាគតអស់កល្ប។ ព្រះគម្ពីរប្រកាសថា ព្រះជាម្ចាស់ *«ជាអាលផា នឹងជាអូមេកា គឺជាដើម ហើយជាចុង»* វិវរណៈ ១:៨។ ព្រះគម្ពីរបញ្ជាក់ថា ព្រះយេស៊ូវជាព្រះជាម្ចាស់ ជាព្រះអទិករ ជាអ្នកគង្វាលដ៏អស្ចារ្យ ជាព្រះអម្ចាស់ ជាព្រះសង្គ្រោះ ជាកូនចៀមនៃព្រះ ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ ជាស្ដេចលើអស់ទាំងស្ដេច ជាព្រះអេម៉ាញ៉ូអែល (ព្រះគង់នៅជាមួយយើង) ជាព្រះសង្គ្រោះ ជាសម្ដេចសង្ឃ និងជាព្រះរស់ពីសុគតឡើងវិញ និងជាជីវិត។

**ព្រះយេស៊ូវជាព្រះអទិករ។** *«កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ ទ្រង់គង់នៅជាមួយនឹងព្រះ តាំងអំពីដើមមក គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្ដារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ...ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា...»* ដកស្រង់ចេញពី យ៉ូហាន ១:១-១៤។ *«ដ្បិតគឺទ្រង់ហើយ ដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ នឹងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់ផង...»* ដកស្រង់ចេញពី កូឡុស ១:១៦-១៧។

**ព្រះយេស៊ូវជាព្រះ «អញគឺជាព្រះដ៏ជាព្រះ»។** ព្រះយេស៊ូវ ជាទេវតារបស់ព្រះអម្ចាស់ បានហៅលោកម៉ូសេចេញពីគុម្ពបន្លាដែលឆេះ នៅក្នុងនិក្ខមនំ ៣ (~១៤៥០មុនគ.ស)។ ព្រះអង្គបានបញ្ជាក់អង្គទ្រង់ថាជា *«ព្រះដ៏ជាព្រះ»*។ នៅក្នុងយ៉ូហាន ៨ ព្រះយេស៊ូវបានប្រកាសអង្គទ្រង់ថា «ព្រះដ៏ជាព្រះ» ព្រះអង្គមាននៅតាំងពីមុនលោកអ័ប្រាហាំ (~២១០០មុនគ.ស) ហើយមាននៅមុនសាសន៍យូដាដែរ។ សាសន៍យូដាឃើញព្រះអង្គប្រកាសថា ជាព្រះដូច្នេះ សាសន៍យូដាបានរើសថ្មគប់ព្រះអង្គតែម្ដង។ ក្រោយមក ព្រះយេស៊ូវបានមានបន្ទូលថា *«ខ្ញុំ ហើយនឹងព្រះវរបិតា គឺតែ១ព្រះអង្គទេ»* យ៉ូហាន ១០:៣០-៣១។ ហើយសាសន៍យូដាបានចោលព្រះអង្គនឹងដុំថ្មម្ដងទៀត។

**ព្រះយេស៊ូវនៅក្នុងគម្ពីរសញ្ញាចាស់។** គ្មាននរណាធ្លាប់មើលឃើញព្រះ ដ៏ជាព្រះវរបិតាទេ យ៉ូហាន ១:១៨, ៦:៤៦។ ប៉ុន្តែ មុនពេលព្រះអង្គចាប់កំណើត ព្រះយេស៊ូវបានលេចមកជាច្រើនដងនៅក្នុងគម្ពីរសញ្ញាចាស់ មុនពេលព្រះអង្គកើតនៅភូមិបេថ្លេហិម។ ព្រះអង្គបានលេចមកក្នុងនាមជាទេវតារបស់ព្រះអម្ចាស់ចំពោះនាងហាកាយ នៅក្នុងលោកុប្បត្តិ ១៦&២១ លេចមកលោកម៉ូសេនៅក្នុងនិក្ខមនំ ៣។ ព្រះយេស៊ូវក៏បានលេចមកឯលោកអ័ប្រាហាំនៅក្នុងលោកុប្បត្តិ ១៧&២២ និងលេចមកឯលោកយ៉ាកុបនៅក្នុងលោកុប្បត្តិ ៣១&៣២។ ហើយព្រះយេស៊ូវត្រូវបាននិយាយថាជាព្រះមួយអង្គនៅក្នុងព្រះត្រៃឯក នៅក្នុងអេសាយ ៤៨:១២-១៩ (ត្រូវបានកត់ត្រាប្រហែល ៧០០ឆ្នាំមុនគ.ស)។

**ព្រះយេស៊ូវជាព្រះដែលត្រូវបានគេទាយទុក។** ជាង៣០០ទំនាយនៅក្នុងគម្ពីរសញ្ញាចាស់ រាប់រយឆ្នាំមុន បានពណ៌នាពីកំណើត ពីជីវិត និងពីការសុគតរបស់ព្រះយេស៊ូវ។ មានទំនាយខ្លះនៅក្នុងគម្ពីរទំនុកតម្កើង ២២ បានពណ៌នាអំពីការឆ្កាងរបស់ព្រះអង្គដ៏គួរឱ្យខ្លាច (ត្រូវបានសរសេរឡើង១០០០ឆ្នាំមុនគ.ស ការចោលនឹងដុំថ្មគឺជាអត្ថន័យនៃការធ្វើគុត)។ ការសម្រេចទំនាយទាំងនោះនៅក្នុង ទំនុកតម្កើង ២២ ត្រូវបានកត់ត្រានៅក្នុងម៉ាថាយ ២៧។

**ព្រះយេស៊ូវបានត្រឡប់ជាមនុស្ស។** នៅក្នុងអេសាយបានទាយថា *«ដ្បិតមានបុត្រ១កើតដល់យើង ព្រះទ្រង់ប្រទានបុត្រា១មកយើងហើយ»* អេសាយ៩:៦។ លោកអេសាយបានបញ្ជាក់ថា ព្រះមួយអង្គនឹងបានជាព្រះដ៏មានគ្រប់ទាំងព្រះចេស្ដា។ ជាបុត្រាដ៏នៅអស់កល្ប ដែលបានប្រទានមកជាបុត្រាដែលប្រសូតមកនៅភូមិបេថ្លេហិម។ ព្រះយេស៊ូវមាននៅមុនពេលព្រះអង្គប្រសូត តាំងពីអស់កល្បរៀងមក។ ឋានៈ «ជាបុត្រារបស់ព្រះ» ពណ៌នាអំពីតួនាទី ជាជាងពណ៌នាអំពីកំណើត។ វាមិនមែនមានន័យថា ព្រះមាននៅ នៅពេលព្រះអង្គប្រសូតនៅបេថ្លេហិមនោះទេ។ លោកសាវកប៉ុលបានសរសេរថា *«ត្រូវតែមានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្ដីដែលស្មើនឹងព្រះនោះ ទុកជាសេចក្ដីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូលស្ដាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់លើឈើឆ្កាងផង»* ភីលីព ២:៥-៨។ ព្រះយេស៊ូវជាមនុស្សពេញលក្ខណៈ ហើយព្រះអង្គក៏ជាព្រះពេញលក្ខណៈដែរ។ ជាព្រះអស់កល្ប ជាព្រះមាននៅមុន ហើយព្រះយេស៊ូវបានយាងចុះមកពីស្ថានសួគ៌ ហើយបានត្រឡប់ជាមនុស្ស យ៉ូហាន ៣:១៣, ៣១; យ៉ូហាន ៦:៣៣-៣៨។ ព្រះយេស៊ូវជាព្រះផង ជាមនុស្សផង។

**ព្រះយេស៊ូវបានធ្វើការអស្ចារ្យ។** ការអស្ចារ្យជាច្រើនរបស់ទ្រង់អាចរកឃើញបាននៅក្នុងគម្ពីរសញ្ញាថ្មី។ កិច្ចការអស្ចារ្យដ៏សំខាន់បីដែលព្រះអង្គបានធ្វើ។ ព្រះអង្គបានចម្អែតមនុស្ស៥០០០នាក់យ៉ាងអស្ចារ្យ ហើយបន្ទាប់មក ព្រះអង្គមានបន្ទូលថា *«ខ្ញុំជានំបុ័ងជីវិត»* យ៉ូហាន ៦:៣៥។ ព្រះអង្គបានប្រោសបុរសខ្វាក់ភ្នែក បន្ទាប់មកព្រះអង្គមានបន្ទូលថា *«កាលខ្ញុំកំពុងតែនៅក្នុងលោកីយនៅឡើយ នោះខ្ញុំជាពន្លឺនៃលោកីយ»* យ៉ូហាន ៩:១-៨។ ហើយព្រះអង្គមានបន្ទូលថា *«ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើស្លាប់ទៅហើយ គង់តែនឹងរស់ឡើងវិញដែរ»* យ៉ូហាន ១១:២៥។ បន្ទាប់មក ព្រះយេស៊ូវបានយាងទៅឯផ្នូរលោកឡាសាជាមិត្តសម្លាញ់របស់ព្រះអង្គ ដែលបានស្លាប់អស់រយៈពេលបួនថ្ងៃហើយ ហើយបានហៅគាត់ឱ្យមានជីវិតរស់ឡើងវិញ។ ព្រះយេស៊ូវបានប្រោសអ្នកឈឺ អ្នកស្វិតដៃជើង មនុស្សថ្លង់ មនុស្សគ មនុស្សឃ្លង់ និងមនុស្សដែលមានអារក្សចូលឱ្យជា។ ព្រះបានធ្វើឱ្យទឹកក្លាយជាទំពាំងបាយជូរ ព្រះអង្គយាងនៅលើទឹក ហើយបង្គាប់សមុទ្រឱ្យស្ងប់។ ម៉ាថាយ ៩:២-៧ ប្រាប់ថា គេបាននាំមនុស្សស្វិតដៃជើងមករកព្រះយេស៊ូវ។

KHEMER

ព្រះអង្គបានមានបន្ទូលទៅបុរសនោះថា «ចូរសង្ឃឹមឡើង កូនអើយ បាបអត់ទោសឱ្យឯងហើយ»។ អ្នកដឹកនាំសាសនាបានគិតថា វាជាការប្រមាថព្រះជាម្ចាស់ ព្រោះមានតែព្រះជាម្ចាស់ទេ ដែលអាចអត់ទោសបាបបាន។ ព្រះយេស៊ូវបានសួរពួកគេថា *«ដ្បិតដែលថា បាបឯងបានអត់ទោសឲ្យឯងហើយ ឬថា ឲ្យក្រោកឡើងដើរទៅ នោះតើពាក្យណាងាយថាជាជាង ប៉ុន្តែ នេះដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា កូនមនុស្សមានអំណាច នឹងអត់ទោសបាបនៅផែនដីបានដែរ នោះទ្រង់មានបន្ទូលទៅអ្នកស្លាប់ដៃស្លាប់ជើងថា ចូរក្រោកឡើង យកគ្រែឯងទៅផ្ទះទៅ ៧អ្នកនោះក៏ក្រោកឡើងដើរទៅឯផ្ទះ»*។

**ព្រះយេស៊ូវបានបង្ហាញថា ព្រះអង្គជាព្រះ។** ព្រះយេស៊ូវបានសម្រេចទំនាយអំពីកំណើត និងការសុគតរបស់ទ្រង់។ ព្រះអង្គបានធ្វើការអស្ចារ្យជាច្រើន ដើម្បីបង្ហាញថា ព្រះអង្គជាព្រះ។ ព្រះអង្គបង្រៀនប្រកបដោយអំណាច។ *«កាលព្រះយេស៊ូវ ទ្រង់មានបន្ទូលសេចក្តីទាំងនេះរួចហើយ នោះបណ្តាមនុស្សក៏នឹកប្លែកពីសេចក្តីដែលទ្រង់បង្រៀន ពីព្រោះទ្រង់បង្រៀន ដូចជាមានអំណាច មិនមែនដូចពួកអាចារ្យរបស់គេទេ»* ម៉ាថាយ ៧:២៨-២៩។ ហើយព្រះអង្គរស់នៅក្នុងជីវិតដែលគ្មានអំពើបាប ហេព្រើរ ៤:១៥, ១ ពេត្រុស ២:២២; ១ យ៉ូហាន ៣:៥។ ព្រះយេស៊ូវជាព្រះដែលកើតជាមនុស្សគ្មានបាប។ *«ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ ជាប់លើឈើឆ្កាង ដើម្បីឲ្យយើងបានរស់ខាងឯសេចក្តីសុចរិត ដោយបានស្លាប់ខាងឯអំពើបាបហើយ គឺដោយស្នាមជាំរបស់ទ្រង់ ដែលអ្នករាល់គ្នាបានជា»* ១ ពត្រ ២:២៤។

**ព្រះយេស៊ូវត្រូវបានឆ្កាង ហើយរស់ពីស្លាប់ឡើងវិញ។** *«ដោយដឹងថា ទ្រង់បានលោះអ្នករាល់គ្នា ឲ្យរួចពីកិរិយាឥតប្រយោជន៍ ដែលបានតពីពួកឰយុកោមក នោះមិនមែនដោយរបស់ពុករលួយ ដូចជាប្រាក់ឬមាសនោះទេ ១៩គឺបានលោះដោយសារព្រះលោហិតដ៏វិសេសរបស់ព្រះគ្រីស្ទវិញ ទុកដូចជាឈាមនៃកូនចៀមឥតខ្ចោះ ឥតស្លាកស្នាម»* ១ ពេត្រុស ១:១៨-១៩។ *«គេបានធ្វើគុតទ្រង់ ដោយព្យួរនៅលើឈើ តែព្រះបានប្រោសឲ្យទ្រង់រស់ឡើងវិញនៅថ្ងៃទី៣ ព្រមទាំងអនុញ្ញាតឲ្យទ្រង់សំដែងមកឲ្យឃើញផង ពួកហោរាសុទ្ធតែធ្វើបន្ទាល់ពីទ្រង់ថា អស់អ្នកណាដែលជឿដល់ទ្រង់ នោះបានរួចពីបាប ដោយសារព្រះនាមទ្រង់»* កិច្ចការ ១០:៣៩-៤០, ៤៣។ *«ដ្បិតមុនដំបូង ខ្ញុំបានប្រាប់មកអ្នករាល់គ្នា តាមសេចក្តីដែលខ្ញុំបានទទួលដែរ គឺថាព្រះគ្រីស្ទបានសុគត ដោយព្រោះបាបរបស់យើងរាល់គ្នា តាមបទគម្ពីរ ហើយថា ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទី៣ នោះទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏តាមបទគម្ពីរ»* ១ កូរិនថូស ១៥:៣-៤។ ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញពីផ្នូរ ហើយមានស្មរបន្ទាល់ជាច្រើនបានឃើញ មុនពេលព្រះអង្គយាងត្រឡប់ទៅស្ថានសួគ៌វិញ។

**ព្រះយេស៊ូវជាផ្លូវតែមួយគត់ទៅរកព្រះជាម្ចាស់។** ព្រះយេស៊ូវមានបន្ទូលថា *«ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ»* យ៉ូហាន ១៤:៦។ លោកសាវកពេត្រុសមានប្រសាសន៍ថា *«ហើយគ្មានសេចក្តីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ»* កិច្ចការ ៤:១២។ លោកសាវកប៉ុលបានសរសេរថា *«ពីព្រោះមានព្រះតែ១ ហើយមានអ្នកសង្រ្គប់សង្រ្គមតែ១ នៅកណ្តាលព្រះ នឹងមនុស្ស គឺជាមនុស្សដ៏ជាព្រះគ្រីស្ទយេស៊ូវនោះ ៦ទ្រង់បានថ្វាយព្រះអង្គទ្រង់ ទុកជាថ្លៃលោះមនុស្សទាំងអស់ ដែលត្រូវមានទីបន្ទាល់នៅពេលកំណត់»* ១ ធីម៉ូថេ ២:៥-៦។ ផ្លូវទៅព្រះរបស់ព្រះយេស៊ូវខុសពីសាសនាផ្សេងៗទាំងអស់។ ផ្លូវរបស់សាសនាផ្សេងៗមិនមានដំណោះស្រាយចំពោះបញ្ហាអំពើបាបរបស់យើងទេ។ ពួកគេបានបង្រៀនថា ប្រសិនបើ អ្នកធ្វើល្អស្រប់តាមនិយមន័យល្អឬអាក្រក់របស់ពួកគេ នោះព្រះរបស់ពួកគេអាចនឹងមើលរំលងអំពើបាបរបស់អ្នក ហើយអនុញ្ញាតឱ្យអ្នកបានចូលទៅស្ថានសួគ៌។ ផ្លូវរបស់ព្រះយេស៊ូវគឺថា តាមរយៈជំនឿលើព្រះអង្គ អំពើបាបរបស់អ្នកត្រូវបានបង់ថ្លៃ នៅលើឈើឆ្កាង និងបានទទួលការអត់ទោស។ ជាមួយព្រះយេស៊ូវ អ្នកបានទទួលការអត់ទោស ហើយបានទៅស្ថានសួគ៌។ *«ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ»* យ៉ូហាន ៣:១៦។

**ព្រះយេស៊ូវនឹងយាងត្រឡប់មកវិញ។** *«កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភឡើយ អ្នករាល់គ្នាជឿដល់ព្រះហើយ ចូរជឿដល់ខ្ញុំដែរ នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំ មានទីលំនៅជាច្រើន ពុំនោះ ខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ ខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា បើខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ»* យ៉ូហាន ១៤:១-៣។ ហើយនៅពាក្យចុងក្រោយនៃព្រះគម្ពីរ ព្រះយេស៊ូវមានបន្ទូលថា *«អើ អញមកជាឆាប់ [ភ្លាម]»*។ លោកសាវកយ៉ូហានបានបន្ថែមទៀតថា *«អាម៉ែន ព្រះអម្ចាស់យេស៊ូវអើយ សូមយាងមក»* វិវរណៈ ២២:២០-២១។ ប្រសិនបើ ព្រះយេស៊ូវយាងមកនៅថ្ងៃនេះ តើអ្នករួចរាល់នឹងជួបព្រះអង្គដែរឬទេ? សូមចូលទៅកាន់គេហទំព័ររបស់យើង www.Gospel316.org ដើម្បីឱ្យប្រាកដថា អ្នករួចរាល់ ដោយជឿលើព្រះយេស៊ូវ ហើយបានទទួលការអត់ទោសពីព្រះ។

**ព្រះយេស៊ូវជាព្រះអស់កល្បពីដើម ដល់អស់លក្បនាពេលអនាគត។**

**ចូរភ្ញាក់ផ្អើល នៅក្នុងភាពអស្ចារ្យនៅពេលនិយាយអំពីព្រះនាមរបស់ទ្រង់!**

*តើព្រះយេស៊ូវជានរណា?* © ២០២៥ ដោយលោក ចន ឌី. ម៉ូរីស III (John D. Morris III) បោះពុម្ពផ្សាយដោយ កិច្ចការមួយប្រាំបី។ អ្នកអាចបោះពុម្ព ថតចម្លង ផុស អ៊ីម៉ែល ឬផ្ញើសារជាមួយនឹងមាតិកាដើម ដោយមិនមានការកែប្រែ ជាមួយសេចក្តីថ្លែងទាំងស្រុងដោយឥតបង់ថ្លៃ។ អ្នកអាចដាក់បន្ថែមព័ន្ធកិច្ច ឬឈ្មោះក្រុមជំនុំ ឬនិមិត្តសញ្ញាតំណាងរបស់អ្នកនៅខាងលើនៃទំព័រទីមួយខាងលើ ហើយបន្ថែមព័ត៌មានទំនាក់ទំនងខាងក្រោមបន្ទាត់ខាងក្រោមនៅទំព័រទីពីរ។ Jesus៣១៦ គឺផ្អែកលើតែព្រះគម្ពីរទេ។ ត្រូវបានបង្កើតឡើងដើម្បីជួយឱ្យមនុស្សបានជឿលើព្រះយេស៊ូវគ្រីស្ទ ហើយបន្ទាប់មកលូតលាស់ទៅជាសិស្សរបស់ព្រះអង្គ។ អ្នកអាចអ៊ីម៉ែលមកកាន់កិច្ចការមួយប្រាំបី (ជាភាសាអង់គ្លេសបើអាច) Hello@Mail316.org. សេវាបកប្រែខុសពីភាសាអង់គ្លេសត្រូវបានផ្តល់ជូនដោយ www.ChristianLingua.com. *តើព្រះយេស៊ូវជានរណា?* មាន៤៨ភាសា ដោយឥតគិតថ្លៃ នៅគេហទំព័រ www.Jesus316.org. ការដកស្រង់ព្រះគម្ពីរជាភាសាអង់គ្លេសគឺដកស្រង់មកពី The Lockman Foundation's New American Standard Bible ១៩៩៥. ហើយព្រះគម្ពីរដែលដកស្រង់នៅក្នុងការបកប្រែនេះគឺចេញពីគម្ពីរ ពគប។